# ការស្ទង់មតិស្តីពីប្រាក់ឈ្នួលក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់៖ ប្រាក់ខែ១០០ដុល្លារក្នុងមួយខែ មិនច្រើនពេកសម្រាប់ការស្នើសុំនោះទេ

## សេចក្តីប្រកាសព័ត៌មាន

**ភ្នំពេញ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣**

មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ ស្វ  មសម្តែងការសោកស្តាយយ៉ាងខ្លាំងចំពោះលទ្ធផលថ្មីៗពីការចរចាប្រាក់ឈ្នួល ក្នុងវិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់។ លើសពីនេះទៅទៀត មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ បានវាយតម្លៃខ្ពស់លើសេចក្តីព្រាងច្បាប់ដែលស្នើឡើងដោយលោក សុន ឆៃ តំណាងរាស្ត្រមកពីគណបក្ស ប្រឆាំង ដែលបានស្នើសុំឲ្យមានប្រាក់ឈ្នួលកម្រិតទាបបំផុតចំនួន១៥០ដុល្លារ ក្នុងមួយខែសម្រាប់កម្មករ-កម្មការិនីខ្មែរ។

យើងស្វ  មគាំទ្រ និងវាយតម្លៃខ្ពស់ចំពោះសេចក្តីព្រាងច្បាប់នេះថា ជាការបោះជំហានឆ្ពោះទៅរកការចាប់ផ្តើមឲ្យមានប្រាក់ឈ្នួលសមរម្យសម្រាប់ទ្រទ្រង់ជីវិភាពរស់នៅ នៅព្រះរាជាណាចក្រកម្ពុជា។ ម្យ៉ាងទៀត ពាក់ព័ន្ធនឹងការបោះឆ្នោតនាពេលខាងមុខនេះ យើងស្វ  មជំរុញសហព័ន្ធពាណិជ្ជកម្ម មេត្តាជួយដល់សមាជិករបស់ខ្លួន ធ្វើយ៉ាងណាឲ្យសមាជិកទាំងនោះ ស្វែងយល់អំពីសំណើសេចក្តីព្រាងច្បាប់នេះ និងអំពីអត្ថប្រយោជន៍ ដែលច្បាប់នេះផ្តល់ជូ  នពួកគាត់។

មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ មានចំណាប់អារម្មណ៍ ថា ការផ្តល់ប្រាក់ឈ្នួលកម្រិតទាបបំផុតនាពេលថ្មីៗនេះចំនួន៧៥ដុល្លារក្នុងមួយខែ នៅមិនទាន់គ្រប់គ្រាន់ទេ។ ផ្អែកលើរបាយការណ៍ យ៉ាងលម្អិត ដែលរៀបចំធ្វើឡើងដោយមូ  លនិធិ Friedrich Ebert Stiftung[1] ានឲ្យ

---

[1] ការស្ទង់មតិអំពីប្រាក់ឈ្នួលយ៉ាងល្អិតល្អន់ នៅឆ្នាំ២០០៩ បានលើកហេតុផលពាក់ព័ន្ធនឹងអតិផរណា។ របាយការណ៍ដែលមានទំហំ២៧ទំព័រនោះត្រូវបានធ្វើឡើងដោយផ្អែកលើការជួបសម្ភាស កម្មករ-កម្មការិនីចំនួន៣៥៣នាក់ នៅតាមរោងចក្រកាត់ដេរសម្លៀកបំពាក់ចំនួន៩ ៧រោងចក្រ នៅរាជធានីភ្នំពេញ និងនៅតំបន់ជាយក្រុ  ងភ្នំពេញ។

ដឹងថា មានតែការដំឡើងប្រាក់ឈ្នួលដល់១០០ដុល្លារ ក្នុងមួយខែប៉ុណ្ណោះដែលកម្មករ-កម្មការិនីខ្មែរធ្វើការនៅតាមរោងចក្រកាត់ដេរសម្លៀកបំពាក់៖

- អាចបន្តទ្រទ្រង់កម្រិតនៃជីវភាពរស់នៅបច្ចុប្បន្ន (ព្រោះប្រាក់ចំណាយលើចំណីអាហារបច្ចុប្បន្ននេះមិនគ្រប់គ្រាន់)
- អាចបង្កើនលទ្ធភាពដើម្បីទ្រទ្រង់សេចក្តីត្រូវការជាមូលដ្ឋានរបស់សមាជិកផ្សេងៗទៀតនៅក្នុងគ្រួសារ
- និង អាចសល់ប្រាក់សន្សំខ្លះទុកសម្រាប់អនាគត។

ថ្មីៗនេះ ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់នៅព្រះរាជាណាចក្រកម្ពុជា ត្រូវបានគេមើលឃើញថា ជាផ្នែកបណ្តាលឲ្យមានភាពក្រីក្រ កង្វះអាហារូបត្ថម្ភ ការកេងប្រវញ្ច និងការជួលសន្លប់ទ្រង់ទ្រាយធំ។ ប្រសិនបើ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសមាគមរោងចក្រកាត់ដេរកម្ពុជា នៅតែបន្តមើលរំលងបញ្ហានេះ ពេលនោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ការដួលសន្លប់ទ្រង់ទ្រាយធំ និងទំនាក់ទំនងផ្នែកឧស្សាហកម្មគួរឲ្យរំខាន នឹងធ្វើឲ្យវិស័យឧស្សាហកម្ម និងជីវភាពរស់នៅរបស់ជនកម្ពុជា លែងមាននិរន្តរភាព។

យើងសូមអំពាវនាវទៅរាជរដ្ឋាភិបាលកម្ពុជា សមាគមរោងចក្រកាត់ដេរកម្ពុជា និងក្រុមហ៊ុនម្ចាស់យីហោអន្តរជាតិល្បីៗដែលផ្តល់លទ្ធភាពឲ្យផលិតសម្លៀកបំពាក់នៅកម្ពុជា ត្រូវធានាបំពេញតាមការទាមទារសុំឲ្យមានការដំឡើងប្រាក់ខែរហូតដល់១០០ដុល្លារក្នុងមួយខែ។

**សម្រាប់ព័ត៌មានបន្ថែមសូម ទាក់ទងមក៖**


១. **លោក មឿន តុលា ប្រធានកម្មវិធីការងារ នៃមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ តាមទូរស័ព្ទលេខ៖ +៨៨៥ ៦៦ ៧៧៧ ០៥៦, ឬ**

២. **លោក Joel Preston ទីប្រឹក្សា មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ តាទូរស័ព្ទលេខ +៨៥៥ ៦៦ ៧៧៧ ០៣៧**


---

របាយការណ៍នេះបានវិភាគយ៉ាងលម្អិតអំពីប្រាក់ចំណាយ និងផលលំបាករបស់កម្មករ។ អាចចូលអានរបាយការណ៍នេះបានតាមអាសយដ្ឋាននេះ៖ http://apirnet.ilo.org/resources/living-wage-survey-for-cambodias-garment-industry.